# សេចក្តីថ្លែងអំណរគុណ

កញ្ចប់សម្ភារៈអាហារល្អ និងសៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួល ដែលត្រូវបានបោះពុម្ពឡើងលើកទីពីរនេះត្រូវបានរៀបរៀងឡើងដោយមានកិច្ចសហការរវាងដៃគូជាច្រើនដែលទទួលបន្ទុកផ្នែកមេរោគអេដស៍ និងអាហារូបត្ថម្ភនៅកម្ពុជា។ ការបោះពុម្ពផ្សាយនេះបង្ហាញនូវកិច្ចប្រឹងប្រែងដ៏ធំធេង និងគួរឲ្យកោតសរសើរនៅក្នុងការកែប្រែឲ្យប្រសើរឡើង និងពង្រីកវិសាលភាពខ្លឹមសារ ដើម្បីឆ្លើយតបទៅតាមគោលនយោបាយ និងគោលគំនិតថ្មីៗពាក់ព័ន្ធនឹងមេរោគអេដស៍ និងអាហារូបត្ថម្ភ។ កិច្ចសម្របសម្រួលនេះត្រូវបានដឹកនាំដោយ វេជ្ជបណ្ឌិត ប្រាក់ សោភ័ណនារី នៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក និងវេជ្ជបណ្ឌិត ឡាន វ៉ាន់សេង នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ រួមសហការជាមួយ ក្រុមការងារស្នូលទទួលបន្ទុកផ្នែកអាហារូបត្ថម្ភសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍។ ការគាំទ្រផ្នែកបច្ចេកទេសត្រូវបានផ្តល់ដោយកម្មវិធីស្បៀងអាហារពិភពលោកកម្ពុជាជាពិសេស លោកស្រី  Dessa Shuckerow និងលោកស្រី ឱន ស៊ាងឡាយ ដោយមានការគាំទ្រពីការិយាល័យប្រចាំតំបន់អាស៊ីនៃកម្មវិធីស្បៀងអាហារពិភពលោក។ ការធ្វើបច្ចុប្បន្នភាពនេះ អាចធ្វើទៅបានដោយសារមានការគាំទ្រពីមូលនិធិសប្បុរសរបស់ UNAIDS។

កញ្ចប់សម្ភារៈអាហារល្អ និងសៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួលនេះត្រូវបានបោះពុម្ពលើកទី១ ក្នុងឆ្នាំ ២០០៩។ ការកែប្រែសម្រួលឡើងវិញក្នុងឆ្នាំ២០១៤ ដោយរួមបញ្ចូលនូវមេរៀនបទពិសោធន៍ដែលទទួលបានពីការអនុវត្តន៍ផ្ទាល់ គោលគំនិតថ្មីៗអំពីអាហារូបត្ថម្ភសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍ និងការផ្លាស់ប្តូរនៅក្នុងគោលនយោបាយជាតិស្តីអំពីមេរោគអេដស៍។ ឯកសារនេះបានពង្រីកវិសាលភាពខ្លឹមសារ ដោយរួមបញ្ចូលនូវក្រុមគោលដៅបន្ថែមរួមមាន ស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូន ដែលមានរស់នៅជាមួយមេរោគអេដស៍ ទារកដែលប្រឈមនឹងមេរោគអេដស៍ កុមាររស់នៅជាមួយមេរោគអេដស៍ និង កុមារកំព្រា និងកុមារងាយរងគ្រោះដោយសារមេរោគអេដស៍/ជំងឺអេដស៍។

សូមថ្លែងអំណរគុណដល់សមាជិកក្រុមការងារស្នូលទទួលបន្ទុកអាហារូបត្ថម្ភសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍ ដែលបានរួមចំណែកនៅក្នុងការកែសម្រួលលើកទីពីរនេះរួមមាន៖ កម្មវិធីជាតិអាហារូបត្ថម្ភ កម្មវិធីបង្ការការឆ្លងមេរោគអេដស៍ពីម្តាយទៅកូន អង្គការ Cambodian HIV/AIDS Education and Care (CHEC) អង្គការ Khmer HIV/AIDS NGO Alliance (KHANA) អង្គការ Caritas អង្គការ CRS (Catholic Relief Service) អង្គការ Family Health International (FHI) 360 អង្គការ Clinton Health Access Initiative (CHAI) អង្គការ Cambodian People living with HIV Network (CPN+) អង្គការ សុខភាពពិភពលោក (WHO) អង្គការយូនីសេហ្វ (UNICEF) និងអង្គការយូអិនអេដស៍ (UNAIDS)។

សូមថ្លែងអំណរគុណដល់ Lia Purnomo, Amanda Justice, Katherine Coote និង Charmaine Turton នៃមជ្ឈមណ្ឌល Albion នៅប្រទេសអូស្ត្រាលី ដែលបានផ្តល់នូវជំនាញបច្ចេកទេស ក្នុងការកែប្រែការបោះពុម្ពផ្សាយលើកទីពីរនេះ និងជឹម ចំរើន សម្រាប់ការថតរូប លម្អរូបភាព និងរចនាទំព័រ។

សូមថ្លែងអំណរគុណជាពិសេសដល់ អ្នកផ្តល់សេវា ក្រុមថែទាំតាមផ្ទះ ក្រុមជួយខ្លួនឯង និងអ្នករស់នៅជាមួយមេរោគអេដស៍ផ្ទាល់ ជាច្រើននាក់ដែលមិនបានរៀបរាប់ឈ្មោះនៅទីនេះ ដែលបានផ្តល់ជាបទពិសោធន៍ជាក់ស្តែងដែលជាមូលដ្ឋាននៃព័ត៌មាននៅក្នុងការបោះពុម្ពផ្សាយលើកទីពីរនេះ។ ជាទីបញ្ចប់ សូមថ្លែងអំណរគុណដោយស្មោះស្ម័គ្រ ម្តងទៀតចំពោះបុគ្គល និងស្ថាប័នទាំងអស់ដែលបានចូលរួមចំណែកនៅក្នុងការបង្កើតឲ្យមាននូវកញ្ចប់សម្ភារៈអាហារល្អ និងសៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួល ដែលបានបោះពុម្ពលើកទីមួយ។